# នកុលជាតក

## សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក
## ទុកនិបាត សន្ថវវគ្គទី ២
## នកុលជាតកទី ៥
## បិដកលេខ ៥៨ ទំព័រ ៧៨
## ព្រមទាំងអដ្ឋកថា

# នកុលជាតក

*ព្រះបរមសាស្តា កាលទ្រង់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធការឈ្លោះគ្នានៃអាមាត្យ ទើបត្រាស់ព្រះធម្មទេសនានេះ ដែលមានពាក្យថា សន្ធឹ កត្វា អមិត្តេន ដូច្នេះជាដើម ។*

*រឿងរ៉ាវទាំងអស់ ដូចរឿងដែលបានពោលទុកហើយក្នុង **ឧរគជាតក** ខាងដើមនោះដែរ ។*

*សូម្បីក្នុងរឿងនេះ ព្រះបរមសាស្តាក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតមិនមែនធ្វើឲ្យមហាមាត្យទាំងពីរនាក់សាមគ្គីគ្នា តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏តថាគតបានធ្វើឲ្យមហាមាត្យទាំងពីរនាក់នេះសាមគ្គីគ្នាដែរ ហើយទើបទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតទៅថា*

*ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ នៅក្នុងក្រុងពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ ក្នុងស្រុកមួយ លុះចម្រើនវ័យហើយ បានទៅរៀនសិល្បៈទាំងពួងក្នុងនគរតក្កសិលា ហើយលះភេទជាឃរាវាស បួសជាតាបស បានញ៉ាំងអភិញ្ញា និង សមាបត្តិ ឲ្យចម្រើន មានមើមឈើ និងផ្លែឈើក្នុងព្រៃជាអាហារ ដោយការត្រាច់ស្វែងរក បានស្នាក់នៅក្នុងព្រៃហិមពាន្ត ។ ខាងចុងនៃទីចង្ក្រមរបស់តាបសពោធិសត្វនោះ មានបំដូកមួយជាទីអាស្រ័យនៅនៃសត្វស្កា ។ នៅជិតដំបូកនោះ មានគល់ឈើមួយជាទីអាស្រ័យនៅនៃសត្វពស់ ។ ពស់ និងស្កាទាំងពីរនោះ ក៏ឈ្លោះគ្នាអស់កាលជានិច្ច ។ ព្រះបរមពោធិសត្វបានពោលអំពីទោសនៃការឈ្លោះគ្នា និងអានិសង្សក្នុងការចម្រើនមេត្តាដល់សត្វទាំងពីរនោះ ហើយទូន្មានប្រៀនប្រដៅ*

ថា មិនគួរឈ្លោះទាស់ទែងគ្នាទេ គួររស់នៅដោយសាមគ្គីគ្នា បានធ្វើឲ្យសត្វទាំងពីរសាមគ្គីគ្នា ។ កាលដល់ពេលពស់ចេញទៅខាងក្រៅ ស្កាក៏ដេកហាមាត់បែរក្បាល់ទៅខាងក្រៅដំបូក នៅខាងចុងទីចង្រ្កម ដកដង្ហើមចេញចូល រួចលក់ទៅត្រង់ទីនោះឯង ។ ព្រះបរមពោធិសត្វឃើញស្កាដេកលក់ កាលនឹងសួរថា កឹំ នុ ខោ តេ និស្សាយ ភយំ ឧប្បន្នំ តើភ័យកើតឡើងដល់អ្នកអំពីទីណា ទើបពោលគាថាទី ១ ថា

សន្ធឹ កត្វា អមិត្តេន អណ្ឌជេន ជលាពុជ
វិវរិយ ឆាបំ សេសិ កុតោ តេ ភយមាគតំ ។

ម្នាលស្កាជាជលាពុជៈ អ្នកធ្វើនូវមិត្តភាពដោយសត្រូវដែលជាអណ្ឌជៈកំណើតហើយ មកដេកបញ្ចេញចង្កូម តើសេចក្តីភ័យ មានមកដល់អ្នកអំពីទីណា ។

បទថា អណ្ឌជេន បានដល់ សត់ដែលកើតក្នុងស៊ុត ។ ហៅស្កាថា ជលាពុជ ដ្បិតថា ស្កានោះហៅថា ជលាពុជៈ ព្រោះកើតក្នុងឡគភ៌ ។

បទថា វិវរិយ ប្រែថា ដេកហាមាត់ ។

កាលព្រះបរមពោធិសត្វពោលយ៉ាងនេះហើយ ស្កាក៏ពោលតបថា បពិត្រលោកម្ចាស់ ឈ្មោះថាសត្រូវមិនគួរមើលងាយ គួររង្កៀសជានិច្ច ហើយពោលគាថាទី ២ ថា

សង្គេថេវ អមិត្តស្មឹ មិត្តស្មិម្បិ ន វិស្សសេ
អភយា ភយមុប្បន្នំ អបិ មូលានិ កន្តតិ ។

*បុគ្គលគប្បីរង្កៀសក្នុងសត្រូវ មិនគប្បីស្និទ្ធស្នាលសូម្បីក្នុងមិត្ត ភ័យដែលកើតឡើងអំពីជនដែលមិនគួរភ័យ រមែងកាត់បង់នូវឫសគល់ទាំងឡាយបាន ។*

*បណ្ដាបទទាំងនោះ បទថា អភយា ភយមុប្បន្នំ បានដល់ ភ័យមិនកើតដល់លោកអំពីឱកាសនេះ ព្រោះហេតុនោះ ទើបឈ្មោះថា មិនមានភ័យ ។*

*សួរថា អ្នកណាទើបឈ្មោះថា ជាមិត្ត ?*

*ឆ្លើយថា បុគ្គលដែលមិនមានភ័យចាត់ថាជាមិត្ត ព្រោះហេតុនោះ ភ័យរមែងកើតឡើងអំពីមិត្តដែលស្និទ្ធស្នាលនោះ រមែងកាត់សូម្បីឫសនោះចោល អធិប្បាយថា រមែងប្រព្រឹត្តទៅដើម្បីកម្ចាត់ឫសគល់ ព្រោះភាពដែលមិត្ត ដឹងចំណុចខ្សោយទាំងអស់ហើយ ។*

*គ្រានោះ ព្រះបរមពោធិសត្វទូន្មានស្កានោះថា អ្នកកុំខ្លាចឡើយ យើងបានធ្វើពស់ឲ្យមិនបៀតបៀនអ្នកទៀតឡើយ ចាប់ពីពេលនេះទៅ អ្នកកុំរង្កៀសនឹងពស់នោះទៀតឡើយ ហើយទូន្មានឲ្យចម្រើនព្រហ្មវិហារ ៤ បែរមុខចំពោះព្រហ្មលោក ។ ក្រោយអំពីចុតិ សត្វទាំងពីរនោះបានទៅតាមយថាកម្ម ។*

ព្រះបរមសាស្តា លុះទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា ពស់និងស្កាក្នុងកាលនោះ បានមកជាអាមាត្យទាំងពីរក្នុងកាលឥឡូវនេះ ចំណែកតាបស គឺ **តថាគត** នេះឯង ។

ចប់ នកុលជាតក ។